# Lawyers' Rights Watch Canada

*អង្គការមិនមែនរដ្ឋាភិបាលក្នុងឋានៈពិគ្រោះយោបល់ពិសេសជាមួយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិ*

ដែលលើកស្ទួយសិទ្ធិមនុស្សតាមរយៈការការពារជនទាំងឡាយដែលការពារសិទ្ធិមនុស្ស

www.lrwc.org – lrwc@portal.ca – ទូរស័ព្ទ៖ +១ ៦០៤ ៧៣៨ ០៣៣៨ – ទូរសារ៖ +១ ៦០៤ ៧៣៦ ១១៧៥

3220 West 13th Avenue, Vancouver, B.C. CANADA V6K 2V5


---

**គោរពជូន**
**ឯកឧត្តម ឌិត មន្ទីរ**
**ប្រធានតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា**

## សារណាស្តីពីសំណុំរឿងអ្នកស្រី យ៉ោម បុប្ផា៖ ការដាក់សំណើជូនតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា

អង្គការឃ្លាំមើលសិទ្ធិមេធាវីកាណាដា ("អ.ស.ម.ក") គឺជាគណៈកម្មាធិការមេធាវីកាណាដា ដែលធ្វើការលើកកម្ពស់សិទ្ធិមនុស្ស និងនីតិរដ្ឋជាអន្តរជាតិ។ អ.ស.ម.ក បានធ្វើការវិភាគទៅលើច្បាប់អន្តរជាតិមួយចំនួនទាក់ទងនឹងសំណុំរឿងរបស់អ្នកស្រី យ៉ោម បុប្ផា។ អ.ស.ម.ក ក៏បានធ្វើញត្តិមួយជូនទៅក្រុមការងារនៃអង្គការសហប្រជាជាតិស្តីពីការឃុំខ្លួនតាមទំនើងចិត្តលើរូបអ្នកស្រី យ៉ោម បុប្ផា ផងដែរ។ អាស្រ័យហេតុនេះ អ.ស.ម.ក សូមដាក់ជូនតុលាការកំពូលនៃព្រះរាជណាចក្រកម្ពុជាដោយក្តីគោរពនូវសំណើដូចខាងក្រោម ក្នុងឱកាសដែលតុលាការកំពូលគ្រោងនឹងជំនុំជម្រះលើសំណុំរឿងរបស់អ្នកស្រី យ៉ោម បុប្ផា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣។

## សាវតារ និងកាលប្បវត្តិ៖

អ្នកស្រី យ៉ោម បុប្ផា គឺជាអ្នកការពារសិទ្ធិមនុស្សមួយរូប។ អ្នកស្រី ជាពលរដ្ឋរស់នៅក្នុងសហគមន៍បឹងកក់ ដែលមានវិវាទដីធ្លីចាប់តាំងពីឆ្នាំ២០០៧ ជាមួយនឹងក្រុមហ៊ុន ហ្សូកាគូ (Shukaku Inc.) របស់លោក ឡៅ ម៉េងឃីន ជាអ្នកជំនួញ និងជាសមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា (គ.ប្រ.ក)។ ក្រោយពីអ្នកស្រីចូលរួមនៅក្នុងការតស៊ូមតិតាមផ្លូវច្បាប់អស់រយៈពេលជាច្រើនឆ្នាំ រួមទាំងការតស៊ូមតិជំនួសឲ្យសកម្មជនសិទ្ធិដីធ្លីមួយចំនួនដែលត្រូវបានឃុំខ្លួន អ្នកស្រី យ៉ោម បុប្ផា ត្រូវបានចាប់ខ្លួន ចោទប្រកាន់ និងផ្តន្ទាទោស។ អ.ស.ម.ក

ពិនិត្យឃើញថា អ្នកស្រី យ៉ោម បុប្ផា ត្រូវបានផ្តន្ទាទោសពីបទចោទប្រកាន់ដែលគ្មានមូលដ្ឋាន នៅក្នុងនីតិវិធី ដែលក្នុងនោះ សាលាដំបូងរាជធានី និងសាលាឧទ្ធរណ៍ បានធ្វើឲ្យមានកំហុសផ្នែកអង្គច្បាប់យ៉ាងធ្ងន់ធ្ងរ រួមទាំងការខកខានក្នុងការគោរពតាមតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានារបស់ព្រះរាជាណាចក្រកម្ពុជា ព្រមទាំងច្បាប់អន្តរជាតិដែលកម្ពុជាមានកាតព្វកិច្ចត្រូវអនុវត្ត។

- ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២៖ អ្នកស្រី យ៉ោម បុប្ផា ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស យោងតាមមាត្រា ២១៧ និង ២១៨ នៃ *ក្រមព្រហ្មទណ្ឌកម្ពុជា*។
- ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២៖ សាលាដំបូងរាជធានីភ្នំពេញ បានបង្គាប់ឲ្យឃុំខ្លួនអ្នកស្រី យ៉ោម បុប្ផា។
- ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១២៖ សាលាឧទ្ធរណ៍បានតម្កល់ដីកាឃុំខ្លួនរបស់សាលាដំបូងទុកជាបានការ និងបានបដិសេធការសុំនៅក្រៅឃុំមុនសវនាការជំនុំជម្រះ។ ពុំមានភ័ស្តុតាងណាមួយដែលត្រូវបានបង្ហាញអំពីការភ័យខ្លាចនៃការរត់គេច ឬហានិភ័យដទៃផ្សេងទៀតដែលមានចែងនៅក្នុងមាត្រា ២០៥ នៃ*ក្រមនីតិវិធីព្រហ្មទណ្ឌ*ឡើយ។ ភ័ស្តុតាងនៃបញ្ហាបេះដូង និងផ្លូវដង្ហើមរបស់អ្នកស្រី យ៉ោម បុប្ផា ត្រូវបានបង្ហាញដោយខ្លួនគាត់ផ្ទាល់។ តុលាការបានលើកសម្អាងហេតុក្នុងការបដិសេធការសុំនៅក្រៅឃុំរបស់អ្នកស្រី យ៉ោម បុប្ផា ថាអ្នកស្រីពុំមានឯកសារពេទ្យណាមួយបញ្ជាក់ថា គាត់មានបញ្ហាសុខភាព និងដោយសារសំណុំរឿងរបស់គាត់មានភាព "ធ្ងន់ធ្ងរពេក"។
- ថ្ងៃទី២៦ និងទី ២៧ ខែធ្នូ ឆ្នាំ២០១២៖ សាលាដំបូងរាជធានីភ្នំពេញបានបើកសវនាការជំនុំជម្រះ។
- ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២៖ អ្នកស្រី យ៉ោម បុប្ផា ត្រូវបានផ្តន្ទាទោសពីបទហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស និងត្រូវទទួលទោសឲ្យជាប់ពន្ធនាគារចំនួនបីឆ្នាំ ព្រមទាំងបង្គាប់ឲ្យបង់ប្រាក់សំណងចំនួន ៣០ លានរៀលទៅឲ្យដើមបណ្តឹងនីមួយៗក្នុងចំណោមដើមបណ្តឹងទាំងពីរ។
- ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣៖ តុលាការកំពូលបានបដិសេធពាក្យសុំនៅក្រៅឃុំ ដោយសម្អាងលើហេតុផលថា ជំងឺបេះដូងរបស់អ្នកស្រី យ៉ោម បុប្ផា មិនត្រូវបានបញ្ជាក់ជាផ្លូវការដោយអាជ្ញាធរផ្នែកសុខាភិបាល អ្នកស្រីត្រូវបានផ្តន្ទាទោសរួចរាល់ហើយ មានការព្រួយបារម្ភថា អាចមានការរត់គេចខ្លួន ហើយសំណុំរឿងនេះគឺជា "សំណុំរឿងពិសេស"។ តុលាការកំពូលមិនបានផ្តល់សម្អាងហេតុណាមួយក្នុងការកំណត់ថា អ្នកស្រី យ៉ោម បុប្ផា អាចនឹងរត់គេចខ្លួន ឬព័ត៌មានណាមួយអំពីអត្ថន័យនៃពាក្យ "សំណុំរឿងពិសេស" ឡើយ។

- ថ្ងៃទី០៤ និងទី ១៥ ខែមិថុនា ឆ្នាំ២០១៣៖ សាលាឧទ្ធរណ៍ បានបើកសវនាការជំនុំជម្រះជាបន្តបន្ទាប់។ ពុំមានអង្គហេតុណាមួយត្រូវបានបង្ហាញ ដើម្បីគាំទ្រដល់ការចោទប្រកាន់ពីបទហិង្សាដោយចេតនាឡើយ។ ដោយគ្មានការជូនដំណឹងជាមុន សាលាឧទ្ធរណ៍បានប្តូរការចោទប្រកាន់ពីបទហិង្សាដោយចេតនាមកជាបទ "សមគំនិត" វិញ ហើយបានសម្រេចផ្តន្ទាទោសលើអ្នកស្រី យ៉ោម បុប្ផា។ ពុំមានភ័ស្តុតាងដោយផ្ទាល់ណាមួយអំពីការសមគំនិតត្រូវបានបង្ហាញនៅសវនាការឧទ្ធរណ៍នោះទេ។ សាលាឧទ្ធរណ៍ បានកាត់បន្ថយទោសជាប់ពន្ធនាគារពីបីឆ្នាំមកត្រឹមពីរឆ្នាំ ប៉ុន្តែតម្កល់សេចក្តីសម្រេចផ្នែកសំណងរដ្ឋប្បវេណី។

## ១. ***ករណីយកិច្ចផ្លូវច្បាប់ដែលតម្រូវដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ*** **("ក.អ.ស.ព.ន"))**[1] **និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ)**[2]

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជានាចក្រកម្ពុជាធានានូវការទទួលស្គាល់សិទ្ធិទាំងឡាយ ដែលត្រូវបានការពារដោយ ក.អ.ស.ព.ន និងធានាថា ការចោទប្រកាន់និងការឃុំខ្លួន ត្រូវតែអនុវត្តយ៉ាងតឹងរ៉ឹងតាមច្បាប់។ មាត្រា ១៥០ នៃរដ្ឋធម្មនុញ្ញ ចែងថា រដ្ឋធម្មនុញ្ញនេះ ជា "ច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា" និងថា "ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត"។

ខ. មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា៖ "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

គ. មាត្រា ៣៨ ចែងថា "... ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់...។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។
ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។

ឃ. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងថា "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ"។

---

[1] មហាសន្និបាតអង្គការសហប្រជាជាតិ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៦ អង្គការសហប្រជាជាតិ កម្រងសន្និសញ្ញា ក្បាល ៩៩៩ ទំព័រ ១៧១ អាចរកបាននៅ៖ http://www.refworld.org/docid/3ae6b3aa0.html [បានចូលមើលនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣] កម្ពុជាបានចូលជាសមាជិកនៃ ICCPR ក្នុងឆ្នាំ១៩៩២ ដោយគ្មានការលើកលែង។

[2] *រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា* ដែលត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ១៩៩៤, ១៩៩៩, ២០០១, ២០០៥, ២០០៦។ សំណៅបកប្រែក្រៅផ្លូវការដែលបានត្រួតពិនិត្យដោយក្រុមប្រឹក្សាធម្មនុញ្ញ ខែមីនា ឆ្នាំ២០១០ អាចរកបាននៅក្រុមប្រឹក្សាធម្មនុញ្ញនៃប្រទេសម្ពុជា៖ http://www.ccc.gov.kh/english/CONSTITUTIONEng.pdf

ង. មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញចែងថា "ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន"។

ច. មាត្រា ១៤(១) នៃ ក.អ.ស.ព.ន ធានាថា "ជនគ្រប់រូប ត្រូវមានឲ្យសាលាក្តីមានសមត្ថកិច្ចឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ចក្នុងវិស័យរដ្ឋប្បវេណី។

**រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ធានាផងដែរនូវតុលាការឯករាជ្យ**

ឆ. មាត្រា ៥១ ចែងថាៈ "ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ...។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ..."។

ជ. មាត្រា ១២៨ ចែងថា "អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ"។

ដូច្នេះ តុលាការត្រូវតែធ្វើសេចក្តីសម្រេចទាំងអស់ ដោយអនុលោមយ៉ាងខ្ជាប់ខ្ជួនតាមច្បាប់ ដោយមិនទទួលរងនូវឥទ្ធិពលពីសមាជិកណាម្នាក់នៃអង្គនីតិប្រតិបត្តិឡើយ ទោះតាមមធ្យោបាយណាក្តី...។

## ២. ការរំលោភបំពានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ យោងតាមច្បាប់អន្តរជាតិ និងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា

សាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ ខកខានមិនបានផ្តល់នូវការជំនុំជម្រះដោយយុត្តិធម៌ អនុលោមតាមលក្ខខណ្ឌតម្រូវនៃ ក.អ.ស.ព.ន និងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាឡើយ។ ក.អ.ស.ព.ន ចែងថាៈ

ក. សេចក្តីសម្រេចទាំងឡាយត្រូវតែផ្អែកលើភ័ស្តុតាងដែលពាក់ព័ន្ធ ដែលត្រូវបានដាក់បង្ហាញ និងបញ្ជាក់នៅក្នុងតុលាការដោយបើកចំហប៉ុណ្ណោះ និងមិនផ្អែកលើទ្រឹស្តីដែលគ្មានការបញ្ជាក់ច្បាស់លាស់ ឬការណែនាំដែលផ្តល់ដោយអាជ្ញាធរនៅពីក្រោយហេតុការណ៍នោះឡើយ (មាត្រា ១៤(៣)(ង) នៃ ក.អ.ស.ព.ន)

ខ. ជនជាប់ចោទត្រូវទទួលបានការជូនដំណឹងឲ្យបានទាន់ពេលវេលាអំពីបទចោទប្រកាន់ និងរាល់ភ័ស្តុតាងដាក់បន្ទុក និងដោះបន្ទុកពាក់ព័ន្ធទាំងអស់ ហើយត្រូវទទួលបានឱកាសក្នុងការបង្ហាញភ័ស្តុតាងដោះបន្ទុក និងបញ្ជាក់អំពីភ័ស្តុតាងដាក់បន្ទុកទាំងអស់ ទោះបីជាធ្វើឡើង

ដោយសាក្សីផ្ទាល់ ឬដោយភស្តុតាងជាឯកសារក៏ដោយ (មាត្រា ១៤(៣)(ង) នៃ ក.អ.ស.ព.ន) និង

គ. ការសម្រេចលើការចោទប្រកាន់ ត្រូវតែធ្វើឡើងដោយសាលាក្តីដែលឯករាជ្យ និងមិនលម្អៀង (មាត្រា ១៤(១) នៃ ក.អ.ស.ព.ន)។

ការខកខានមិនបានការគោរពតាមបទប្បញ្ញត្តិទាំងនេះ ជាកំហុសផ្នែកអង្គច្បាប់។ការផ្តន្ទាទោសលើអ្នកស្រី យ៉ោម បុប្ផា ពីបទ "ហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស" ធ្វើឡើងផ្ទុយទៅនឹងភស្តុតាង។ សាលក្រមដែលរកឃើញពីពិរុទ្ធភាពរបស់អ្នកស្រី ត្រូវបានធ្វើឡើង ក្រោយពីសាលាដំបូងរាជធានីបានពិនិត្យភស្តុតាងដែលមិនអាចប្រកែកបានថា ទាំងអ្នកស្រី យ៉ោម បុប្ផា និងស្វាមីរបស់អ្នកស្រីមិនបានចូលរួមនៅក្នុងការបង្ករបួសស្នាម កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ នោះទេ។ ពុំមានភស្តុតាងណាមួយត្រូវបានបង្ហាញដើម្បីគាំទ្រការសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដែលថា ជនជាប់ចោទបានសមគំនិតក្នុងការ "រៀបចំផែនការ" បង្ករបួសស្នាមដល់អ្នកដទៃនោះទេ។ សាលាឧទ្ធរណ៍បានបន្ថែមការចោទប្រកាន់ពីបទសមគំនិតដែលយល់ស្របតាមការសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ទោះបីជាការសន្និដ្ឋាននេះធ្វើឡើងដោយពុំមានភស្តុតាងក៏ដោយ។

នៅក្នុងសវនាការជំនុំជម្រះ អ្នកស្រី យ៉ោម បុប្ផា ពុំបានទទួលការជូនដំណឹងអំពីការចោទប្រកាន់ពីបទសមគំនិតឡើយ ហើយគាត់ក៏មិនត្រូវបានចោទប្រកាន់ពីបទសមគំនិតក្នុងការរៀបចំផែនការបង្ករបួសស្នាមនៅសវនាការសាលាដំបូងរាជធានី ឬសវនាការសាលាឧទ្ធរណ៍នោះទេ។ ពុំមានការជូនដំណឹងអំពីការចោទប្រកាន់ពីបទសមគំនិតត្រូវបានផ្តល់ជូនមុនពេលសវនាការសាលាឧទ្ធរណ៍ឡើយ។ ភស្តុតាងដែលបានលើកឡើងនៅសាលាឧទ្ធរណ៍គឺថា អ្នកស្រី យ៉ោម បុប្ផា បានចោទប្រកាន់ជនរងគ្រោះម្នាក់ពីបទលួចកញ្ចក់រថយន្តរបស់គាត់ និងថា គាត់បានជួយរំដោះអ្នកបង្ករបួសស្នាមម្នាក់។ ភស្តុតាងនេះត្រូវបានជំទាស់ និងមិនត្រូវបានបញ្ជាក់ថាត្រឹមត្រូវឡើយ។ អ្នកស្រី យ៉ោម បុប្ផា នៅតែស្ថិតនៅក្នុងពន្ធនាគារនៅឡើយ ទោះបីជាពុំមានភស្តុតាងគ្រប់គ្រាន់ថា គាត់បានប្រព្រឹត្តទង្វើខុសច្បាប់យ៉ាងណាក្តី។

គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (គណៈកម្មាធិការសិទ្ធិមនុស្ស) នៅក្នុង*បទអត្ថាធិប្បាយទូទៅលេខ ១៣(៨)* បានបញ្ជាក់ថា លក្ខខណ្ឌតម្រូវអំពីការជូនដំណឹងនៃមាត្រា ១៤(៣) រួមបញ្ចូលទាំង៖

៨. …បុគ្គលគ្រប់រូបមានសិទ្ធិត្រូវទទួលបាននូវព័ត៌មានអំពីការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ…។ មាត្រា ១៤ (៣) (ក) អនុវត្តចំពោះគ្រប់ករណីទាំងអស់នៃ

ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ រួមទាំងរឿងក្តីរបស់ជនទាំងឡាយណាដែលមិនជាប់ឃុំ... សិទ្ធិត្រូវបានព័ត៌មាន "ភ្លាមៗ" អំពីការចោទប្រកាន់ តម្រូវថា ព័ត៌មានត្រូវបានផ្តល់ជូនតាមរបៀបដែលបញ្ជាក់ ភ្លាមៗនៅពេលដែលការចោទប្រកាន់ត្រូវបានធ្វើឡើងពីដំបូងដោយអាជ្ញាធរមានសមត្ថកិច្ច.... សិទ្ធិនេះត្រូវកើតឡើងនៅពេលតុលាការ ឬស្ថាប័នអយ្យការ ក្នុងអំឡុងដំណើរការស៊ើបអង្កេត សម្រេចចាត់វិធានការតាមនីតិវិធីប្រឆាំងនឹងជនណាម្នាក់ដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស ឬកំណត់មុខសញ្ញាជននោះជាសាធារណៈ ...។

អ្នកស្រី យ៉ោម បុប្ផា មិនបានទទួលការជូនដំណឹងភ្លាម ឬការជូនដំណឹងណាមួយអំពីការចោទប្រកាន់ពីបទសមគំនិតបង្ករបួសស្នាម មុនពេលសវនាការជំនុំជម្រះសាលាដំបូង ឬសវនាការជំនុំជម្រះនៅសាលាឧទ្ធរណ៍ ដូចដែលតម្រូវដោយមាត្រា ១៤ នៃ ក.អ.ស.ព.ន និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ។

**៣. ការរំលោភបំពានលើការសន្មតអំពីភាពគ្មានទោស នៅក្នុងដំណើរការមុនពេលជំនុំជម្រះទាំងមូល ក្នុងអំឡុងពេលជំនុំជម្រះ និងរង់ចាំការជំនុំជម្រះនៅសាលាឧទ្ធរណ៍ ការមិនបានគោរពតាមលក្ខខណ្ឌតម្រូវរបស់ ក.អ.ស.ព.ន[3] និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ)[4]**

សាលាដំបូងរាជធានី (នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២) និងសាលាឧទ្ធរណ៍ (នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១២) មិនបានធ្វើការពិចារណាឲ្យបានត្រឹមត្រូវលើសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស នៅពេលពិចារណាលើពាក្យសុំនៅក្រៅឃុំ។ តុលាការកំពូល (នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣) មិនបានធ្វើការពិចារណាឲ្យបានត្រឹមត្រូវលើសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស នៅពេលសំណុំរឿងរបស់អ្នកស្រី យ៉ោម បុប្ផា កំពុងរង់ចាំសវនាការជំនុំជម្រះនៅសាលាឧទ្ធរណ៍ឡើយ។

ក.អ.ស.ព.ន ធានានូវសិទ្ធិរបស់មនុស្សគ្រប់រូបដែលត្រូវទទួលបានការសន្មតជាមុនថាគ្មានទោស (មាត្រា ១៤(២))។ សិទ្ធិនេះរួមទាំងសិទ្ធិមានសេរីភាព "លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់" (មាត្រា ៩ នៃ ក.អ.ស.ព.ន)។ ដូចដែលបានបញ្ជាក់នៅក្នុងបទអត្ថាធិប្បាយទូទៅទី៨ ដោយគណៈកម្មាធិការសិទ្ធិមនុស្ស (ឆ្នាំ១៩៨២)

---

[3] *Albert Womah Mukong v. Cameroon* (458/1991), ត្រង់កថាខណ្ឌទី ៩.៨, ត្រូវបានអះអាងឡើងវិញ *ក្នុងចំណោមសៀវភៅផ្សេងទៀត* ក្នុង *Abdelhamid Taright, Ahmed Touadi, Mohamed Remli and Amar Yousfi v. Algeria* (1085/2002), ត្រង់កថាខណ្ឌទី ៨.៣, and *Rafael Marques de Morais v. Angola (1128/2002),* ត្រង់កថាខណ្ឌទី ៦.១. ៦.១។

ការឃុំខ្លួនបណ្ដោះអាសន្នត្រូវតែធ្វើដោយមានកម្រិត និងអនុវត្តតែនៅក្នុងកាលៈទេសៈពិសេស ដែលមានចែងដោយច្បាប់ប៉ុណ្ណោះ។

គណៈកម្មាធិការសិទ្ធិមនុស្សបានពន្យល់ ទាក់ទងនឹងការឃុំខ្លួនតាមទំនើងចិត្តថា៖

> ប្រវត្តិនៃការតាក់តែងសេចក្ដីព្រាងនៃមាត្រា ៩ កថាខណ្ឌទី ១ បញ្ជាក់ថា "ការធ្វើតាមទំនើងចិត្ត" មិនមានន័យស្មើនឹង "ប្រឆាំងនឹងច្បាប់" ទេ ប៉ុន្តែត្រូវតែបកស្រាយឲ្យបានទូលំទូលាយជាងនេះដើម្បីរួមបញ្ចូលទាំងធាតុនានានៃភាពមិនសមស្រប ភាពអយុត្តិធម៌ កង្វះការសន្មត និងដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់។ នៅពេលគណៈកម្មាធិការសិទ្ធិមនុស្សបានធ្វើការអង្កេតលើស្ថានភាពកើតឡើងពីមុនៗ ចំណុចនេះមានន័យថា ការឃុំខ្លួន អនុលោមតាមការចាប់ខ្លួនដោយស្របច្បាប់ មិនត្រឹមតែស្របច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសមហេតុផល នៅក្នុងគ្រប់កាលៈទេសៈទាំងអស់។ ការឃុំខ្លួនត្រូវតែជាការចាំបាច់នៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ឧទាហរណ៍ ដើម្បីបង្ការការរត់គេចខ្លួន បង្ការការការរំខានដល់ភ័ស្តុតាង ឬបង្ការបទល្មើសកុំឲ្យកើតឡើងជាថ្មី។[3]

សេចក្ដីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១២ សេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១២ និងសេចក្ដីសម្រេចរបស់តុលាការកំពូល នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៣ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់តាមច្បាប់ជាតិ និងច្បាប់អន្តរជាតិឡើយ។ មាត្រា ៤៨ មាត្រា ២០៣ និងមាត្រា ២០៥ នៃ *ក្រមនីតិវិធីព្រហ្មទណ្ឌ* រដ្ឋធម្មនុញ្ញ និង ក.អ.ស.ព.ន តម្រូវឲ្យតុលាការកម្ពុជាធានាថា ការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានអនុវត្ត តែនៅក្នុងករណី ដែលការឃុំខ្លួនបណ្ដោះអាសន្ននេះត្រូវបានបង្កើតឡើងជាការចាំបាច់ ដើម្បីបង្ការហានិភ័យដែលមានការបញ្ជាក់ ដូចជា៖ ការរត់គេចខ្លួន ជ្រៀតជ្រែកដល់ការគ្រប់គ្រងលើវិស័យយុត្តិធម៌ ឬការកើតឡើងជាថ្មីនៃបទល្មើសដែលត្រូវបានចោទប្រកាន់។ តុលាការក៏ត្រូវតែយល់ឃើញដោយផ្អែកលើមូលដ្ឋានតាមផ្លូវច្បាប់ផងដែរថា ពុំមានជម្រើសផ្សេងក្រៅពីការឃុំខ្លួនបណ្ដោះអាសន្ន ដែលអាចបង្ការហានិភ័យនានាដែលត្រូវបានបញ្ជាក់ឡើយ។ នៅក្នុងសំណុំរឿងរបស់អ្នកស្រី យ៉ោម បុប្ផា តុលាការបានដាក់កាតព្វកិច្ចដោយមិនត្រឹមត្រូវលើអ្នកស្រី យ៉ោម បុប្ផា ឲ្យអ្នកស្រីត្រូវបង្ហាញភ័ស្តុតាងថា ស្ថានភាពសុខភាពរបស់គាត់តម្រូវឲ្យមានការដោះលែង។

ការខកខានរបស់តុលាការក្នុងការអនុវត្តន៍ឲ្យបានត្រឹមត្រូវនូវច្បាប់ ដែលការពារសិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស ព្រមទាំងច្បាប់ទាក់ទងនឹងការស្នើសុំនៅក្រៅឃុំ ជាកំហុសផ្នែកអង្គច្បាប់។ ការបដិសេធម្ដងហើយម្ដងទៀតចំពោះពាក្យសុំនៅក្រៅឃុំ ដោយពុំមានយុត្តិកម្មតាមផ្លូវច្បាប់ គឺស្របទៅនឹងការវិភាគ ដែលបានលើកឡើង

ដោយអ្នកសង្កេតការណ៍មួយចំនួន ពោលគឺ ការចោទប្រកាន់មិនបានធ្វើឡើងក្នុងគោលបំណងអនុវត្តច្បាប់នោះទេ ប៉ុន្តែបែរជាធ្វើទៅក្នុងគោលបំណងមិនត្រឹមត្រូវដើម្បីដាក់ទណ្ឌកម្ម និងការរារាំងដល់ការតស៊ូមតិផ្នែកសិទ្ធិមនុស្សស្របច្បាប់របស់អ្នកស្រី យ៉ោម បុប្ផា ទៅវិញ។

## ៤. កង្វះភាពឯករាជ្យ និងភាពមិនលម្អៀងរបស់តុលាការ

ការផ្តន្ទាទោសលើអ្នកស្រី យ៉ោម បុប្ផា ដោយផ្អែកលើភ័ស្តុតាងដាក់បន្ទុកមិនស៊ីសង្វាក់ និងគ្មានសម្អាងហេតុត្រឹមត្រូវ នៅចំពោះភ័ស្តុតាងដោះបន្ទុកដែលមានសម្អាងត្រឹមត្រូវ និងមិនអាចជំទាស់បាន ជាការកាត់សេចក្តីខុសទាំងស្រុងរបស់តុលាការ ហើយត្រូវតែចាត់ទុកសេចក្តីសម្រេចទាំងនោះថាពុំត្រឹមត្រូវ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធាន មេត្តាទទួលយកពិចារណានូវសារណាសន្និដ្ឋានរបស់យើងខ្ញុំដោយក្តីអនុគ្រោះ។

សូមឯកឧត្តមប្រធាន ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣

**ហ្គេល ដេវីឌសុន**
នាយកប្រតិបត្តិ
អង្គការឃ្លាំមើលសិទ្ធិមេធាវី កាណាដា
(Lawyers′ Rights Watch Canada)

ចម្លងជូន៖ ឯកឧត្តម **អង្គ វង្សវឌ្ឍានា**
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
លេខ ២៤០ មហាវិថីសុធារស
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសារ៖ ០២៣ ៣៦៤១១៩ អ៊ីមែល៖ moj@cambodia.gov.kh

ចម្លងជូន៖ លោកជំទាវ **ជា លាង**
អគ្គព្រះរាជអាជ្ញា
តុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា
ផ្លូវសុធារស និងផ្លូវលេខ ២៤០ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា